ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥ ០.១៤ ១៤១ ធ.ជ.ស.ហ

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី ១៧

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃអង្គារ ៦កើត ខែផល្គុន នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាព : ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន នព្វស័ក ព.ស. ២៥៦១ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨
- កាលប្រតិទាន : ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩
- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមាក្នុងមួយគ្រឹះស្ថាន : មិនកំណត់
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD (ជារៀលឬដុល្លារអាមេរិក) ត្រូវមានកាលប្រតិទានយ៉ាងតិច៣៦៤ថ្ងៃ។ NCD ជាដុល្លារអាមេរិកត្រូវកំណត់ Haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP)។ ក្នុងករណីផ្លែតហ្វមនេះមិនអាចអនុវត្តបាន ត្រូវបញ្ជូនតាមសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការឲ្យបានមុនម៉ោង ១២:០០ ថ្ងៃត្រង់នាថ្ងៃដដែល។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

ព្រះរាជាណាចក្រកម្ពុជា
ធនាគារជាតិនៃកម្ពុជា

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh